ដែលរស់នៅក្នុងអង្គភាពសេដ្ឋកិច្ចមួយ (បានសេចក្តីថា ជួយចេញថ្លៃចាយវាយ) ថាជាគ្រួសារតែ១ ។ ដូច្នេះ ប្រាក់ចំណូលដែលរាយការនៅក្នុងពាក្យទទួលប្រាក់កម្រៃម្ហូបអាហារនោះ(Meal Benefit Form) ចាំបាច់ត្រូវតែ បញ្ចូលទាំង ប្រាក់ចំណូលមិនទាន់ហូតពន្ធដារ របស់សមាជិកទាំងអស់ នៅក្នុងគ្រួសាររបស់លោកអ្នក តាមប្រភពនិមួយៗ ។

ប្រាក់ចំណូល ដែលលោកអ្នករាយការ ចាំបាច់ត្រូវតែជា ប្រាក់ចំណូលទាំងអស់មុនការដកហូតពន្ធដារចេញ តាមប្រភពនិមួយៗ សម្រាប់សមាជិកគ្រួសារម្នាក់ៗ ដែលបានទទួលកាលពីខែមុន ។ ប្រសិនបើប្រាក់ចំណូលពីខែមុន មិនឆ្លុះបញ្ចាំងនូវកាលះទេសះ របស់លោកអ្នក ឱយបានពិតប្រកដទេនោះ លោកអ្នកអាច ដាក់ចំនួនដែលលោកអ្នក ទស្សន៏ទាយថាជាប្រាក់ចំណូលប្រចាំខែ របស់លោកអ្នកនោះ ។ ប្រសិនបើគ្មានការផ្លាស់ប្តូរអ្វីធំដុំកើតឡើងទេនោះ លោកអ្នកអាចយក ប្រាក់ចំណូលកាលពីខែមុន មកធ្វើជាគោលមួយសម្រាប់ ធ្វើការទស្សន៏ទាយនេះ ។ ប្រសិនបើប្រាក់ចំណូលក្នុងក្រុមគ្រួសារ របស់លោកអ្នក ស្មើ ឬមួយក៏តិចជាង ចំនួនដែលបង្ហាញសម្រាប់ ទំហំ នៃក្រុមគ្រួសារលោកអ្នក នៅក្នុងតារាងប្រាក់ចំណូល ដែលផ្ជាប់ជាមួយគ្នានេះ លោកអ្នកនិងទទួល បានប្រាក់កម្រៃច្រើនជាងថែមទៀត ។

បទបញ្ជាតម្រូវឱយលោកអ្នក រាយការប្រាប់ឱយយើងខ្ញុំបានដឹង ប្រសិនបើប្រាក់ចំណូលរបស់លោកអ្នក កើនឡើងក្នុងអម្ពុងឆ្នាំនេះ ។ ការចុះថយ នៅក្នុងទំហំគ្រួសារ ឬ ការកើនប្រាក់ចំណូល ដែលលើសពី ៥០ ដុល្លារ ក្នុងមួយខែ ឬ លើសពី ៦០០ ដុល្លារ ក្នុងមួយឆ្នាំ ចាំបាច់ត្រូវតែរាយការឱយដឹង ។ ប្រសិនលោកអ្នកផ្តល់ភស្តុតាង បង្ហាញនូវការទទួលបានប្រាក់កម្រៃ ហើយ រាយការអំពីប្រាក់ FOOD STAMP ប្រាក់ជំនួយជាបណ្តោះអាសន្ន៍ សម្រាប់គ្រួសារក្រីក្រ (TANF) ឬ លេខកម្មវិធីចែកចាយម្ហូបអាហារ នៅកន្លែងរស់នៅសម្រាប់ជនជាតិ ស្បែកក្រហមនោះ(FDPIR) លោកអ្នកចាំបាច់ត្រូវតែ ប្រាប់ឱយយើងខ្ញុំបានដឹងដែរ ថាតើនៅពេលណាដែល លោកអ្នកឈប់ទទួល ប្រាក់កម្រៃទាំងនោះ ។ លោកអ្នកគួរតែប្រាប់ឱយយើងដឹងផងដែរ ប្រសិនបើលោកអ្នកគ្មានការងារធ្វើ ហើយ ការបាត់បង់ប្រាក់ចំណូល ក្នុងអម្ពុងពេលគ្មានការងារធ្វើនេះ នាំឱយប្រាក់ចំណូលក្នុងគ្រួសាររបស់លោកអ្នក ធ្លាក់ចុះដល់កម្រិតអាចទទួលបានប្រាក់កម្រៃនោះ។